# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអគ្គសញ្ញាលាបថ្ងាសនៅបឹងទំពុន
# ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៨
## *ឲ្យដៃ ជើង ភ្នែករបស់យើងពោរពេញដោយធម៌មេត្តាករុណា*

អត្ថបទទី១៖ ជរ ១១,២៥-២៩
អត្ថបទទី២៖ យក ៥,១-៦
ដំណឹងល្អ៖ មក ៩,៣៨-៤៣.៤៥.៤៧-៤៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះព្រះយេស៊ូនិយាយសាហាវណាស់ ព្រះយេស៊ូណែនាំឲ្យយើងកាត់ដៃប្រសិនបើដៃយើងប្រព្រឹត្តអំពើបាប ឲ្យយើងកាត់ជើងប្រសិនបើជើងយើងប្រព្រឹត្តអំពើបាប ឲ្យយើងខ្វិះភ្នែកប្រសិនបើភ្នែកយើងប្រព្រឹត្តអំពើបាប។ ពេញមួយអាទិត្យនៅសហរដ្ឋអាមេរិកអ្នកដឹកនាំពិភពលោក គេបានជួបជុំគ្នាដើម្បីគិតអំពីស្ថានភាពពិភពលោក មាន១៥២ប្រទេសបានចូលរួម។ ១៥២នាក់ដែលបានជួបជុំគ្នា សព្វថ្ងៃស្ថានភាពនៃពិភពលោកយើងយ៉ាងមិច? ពួកគេបាននិយាយអំពីបញ្ហាសង្គ្រាម ទាំងសង្គ្រាមប្រើអាវុធ និងសង្គ្រាមមិនប្រើអាវុធ។ គេបាននិយាយអំពីបញ្ហាបរិស្ថាន សព្វថ្ងៃពិភពលោករបស់យើងគេកំពុងភ័យខ្លាចជាមួយគ្រោះថ្នាក់ធម្មជាតិផ្សេងៗ។ អ្វីៗទាំងអស់ដែលកើតឡើងនៅក្នុងពិភពលោកទាំងមូល ណែនាំឲ្យមនុស្សយើងភ័យខ្លាច ព្រោះថាអ្វីៗទាំងអស់មានឥទ្ធិពលលើជីវិតរបស់យើងផ្ទាល់ដែរ។

នៅពេលយើងឃើញមានសង្គ្រាម មានគ្រោះធម្មជាតិ អ្វីៗទាំងអស់កើតឡើងដោយសារអ្នកណា? អ្វីៗទាំងអស់កើតឡើងដោយសារអ្វី? ពីដើមព្រះជាម្ចាស់បានបង្កើតពិភពលោក បានបង្កើតមនុស្សលោក បានបង្កើតធម្មជាតិ ដើម្បីឲ្យមនុស្សយើងរស់នៅក្នុងសេចក្ដីសុខ នៅក្នុងសុភមង្គល នៅក្នុងសេចក្ដីសង្ឃឹម នៅក្នុងជីវិតដែលពោរពេញដោយសេចក្ដីស្រឡាញ់។ នេះជាគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ សព្វថ្ងៃយើងឃើញស្ថានភាពនៃពិភពលោកពិបាកទៅៗ។ មានប្រទេសខ្លះគេកំពុងគិត តើគេមានសិទ្ធិអនុញ្ញាតឲ្យប្រជាជនម្នាក់ដែលអស់កម្លាំងនៅក្នុងជីវិត ឬជាអ្នកជំងឺយ៉ាងធ្ងន់សម្លាប់ខ្លួនជាផ្លូវការ?

ប៉ុន្តែអ្វីៗទាំងអស់ដែលយើងទទួលនៅក្នុងដៃរបស់យើង ទាំងធម្មជាតិ ទាំងបរិស្ថាន ទាំងមនុស្ស ជាព្រះអំណោយទានដែលយើងទទួលពីព្រះជាម្ចាស់។ ប្រសិនបើព្រះយេស៊ូបានចូលរួមនៅក្នុងអង្គប្រជុំហ្នឹង តើព្រះយេស៊ូនឹងនិយាយអ្វីដល់អ្នកដឹកនាំពិភពលោក? ដូចក្នុងគម្ពីរដែលយើងបានស្ដាប់ថ្ងៃនេះ **"ក្នុងនាមអ្នករាល់គ្នាជាសិស្សរបស់ព្រះគ្រីស្ដ ខ្ញុំសុំប្រាប់អ្នកអ្នករាល់គ្នាដឹងច្បាស់ថា ប្រសិនបើអ្នកណាឲ្យទឹកមួយកែវដល់អ្នករាល់គ្នា អ្នកនោះនឹងទទួលរង្វាន់ជាមិនខាន"**។

ព្រះយេស៊ូនិយាយអ្វីដែលសំខាន់បំផុត ឲ្យយើងយកចិត្តទុកដាក់ជាមួយបងប្អូនឯទៀតៗ ស្រឡាញ់មនុស្សទាំងអស់ ដើម្បីបង្កើតពិភពមួយដែលពោរពេញដោយសេចក្តីសុខ។ ដោយសារ ប្រភពនៃសង្គ្រាម មកពីចិត្តលោភលន់របស់មនុស្ស ដែលណែនាំឲ្យពិភពរបស់យើងសព្វថ្ងៃមាន ទុក្ខលំបាក មានមនុស្សជាច្រើនស្លាប់ដោយគ្មានមូលហេតុសមរម។ ប៉ុន្តែ ថ្ងៃនេះព្រះយេស៊ូបាន និយាយដល់យើងម្នាក់ៗ កុំឲ្យយើងភ្លេច បើយើងឲ្យទឹកមួយកែវដល់បងប្អូនរបស់ខ្ញុំដោយចិត្ត ស្រឡាញ់ នៅពេលនោះខ្ញុំបានអនុវត្តគម្រោងការរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់មនុស្ស លោក។

ប្រសិនបើ**ដៃ**របស់យើង ណែនាំឲ្យមនុស្សតូចតាចម្នាក់រងទុក្ខលំបាក ឲ្យយើងកាត់ដៃ ចោលទៅ ឲ្យយើងបើកដៃដើម្បីជួយ ដើម្បីបម្រើ ដើម្បីឲ្យសេចក្តីសុខសាន្តនិងសេចក្តីស្រឡាញ់ ទៅគ្រប់ទីកន្លែង។ កុំឲ្យយើងប្រដៃដើម្បីណែនាំឲ្យអ្នកដទៃពិបាក ឲ្យយើងដឹងថាយើងមិនមែនជា អ្នកដឹកនាំពិភពលោក ប៉ុន្តែនៅកន្លែងដែលយើងរស់នៅសព្វថ្ងៃ យើងមានសមត្ថភាពដោយសារ ព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅជាមួយយើង ដើម្បីបង្កើតសេចក្តីសុខដោយដៃរបស់យើង។ បើ ដៃរបស់យើងចេះជួយគេ ដៃរបស់យើងចេះលើកទឹកចិត្ត ដៃរបស់យើចេះចែករំលែកធម៌មេត្តា ករុណារបស់ព្រះជាម្ចាស់។

**ភ្នែក**ដែលមើលងាយគេ ភ្នែកដែលប្រព្រឹត្តអំពើបាប ព្រះយេស៊ូឲ្យខ្វិះចេញ ព្រះយេស៊ូថា សុំមានភ្នែកដូចខ្ញុំ។ យើងនឹកឃើញរបៀបព្រះយេស៊ូ ប៉ុន្មានដងប៉ុន្មានសារ ព្រះយេស៊ូបានទត មើលគេដោយព្រះហឫទ័យមេត្តាករុណា កុំឲ្យយើងបុរេវិនិច្ឆ័យលឿនពេក ឲ្យយើងចូលនៅក្នុង ខ្លួនរបស់មនុស្ស ដើម្បីពិចារណា ដើម្បីដឹងថាមនុស្សម្នាក់មានអំណោយទានរបស់ព្រះជាម្ចាស់ មានវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងគាត់ ឲ្យធ្វើដូចម្តេចដើម្បីមើលគាត់ ដូចព្រះយេស៊ូបានមើល យើង។

**ជើង**របស់យើង បើវាប្រព្រឹត្តអំពើអាក្រក់ ជិះជាន់គេព្រះយេស៊ូឲ្យកាត់ចោលទៅ ព្រះ យេស៊ូឲ្យយើងប្រើជើងរបស់យើងដើម្បីដើរទៅសួរសុខទុក្ខ លើកទឹកចិត្ត ដើម្បីដើរជួបអ្នកដែល មានទុក្ខលំបាក។ ជើងរបស់យើង ណែនាំឲ្យយើងមានសេរីភាពដើម្បីធ្វើដំណើរ ជីវិតរបស់ព្រះ យេស៊ូគឺដើម្បីធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ។ យើងប្រើជើងដើម្បីដើរទៅគ្រប់ទីកន្លែង យើងមិនមែនប្រើជើងដើម្បីជិះជាន់ យើងប្រើជើងដើម្បីដើររកបងប្អូនឯទៀតៗដែលទន្ទឹងរង់ចាំ សេចក្តីសុខ និងសេចក្តីសង្ឃឹម។ នេះណែនាំឲ្យយើងទៅជាសាក្សីនៃជីវិតថ្មី ដែលព្រះយេស៊ូ សង្ឃឹមសម្រាប់មនុស្សលោក។

អ្វីៗដែលយើងបានស្តាប់ របាយការណ៍អ្នកដឹកនាំឈ្លោះគ្នាផង អន់ចិត្តគ្នាផង បង្កើតសង្គ្រាមផង ណែនាំឲ្យពិភពលោករបស់យើងវង្វេងអស់ហើយ។ តែយើងមិនអស់សង្ឃឹមទេ យើងជាគ្រីស្តបរិស័ទ យើងមានព្រះបិតាដែលគង់នៅជាមួយផ្ទាល់ ដែលគង់នៅជាមួយពិភពលោកទាំងមូល ដើម្បីណែនាំឲ្យពិភពនេះពោរពេញដោយសេចក្តីសុខ។ អត្ថបទទី១ "**មូលហេតុអ្វីព្រះជាម្ចាស់ចែកវិញ្ញាណឲ្យគេដែរ**" លោកម៉ូសេបានឆ្លើយតបគេវិញថា "**តើអ្នកមានចិត្តច្រណែនជំនួសខ្ញុំឬ? សូមឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទៅជាព្យាការីទាំងអស់គ្នា សូមព្រះអម្ចាស់ប្រទានវិញ្ញាណរបស់ព្រះអង្គឲ្យមកស្ថិតលើពួកគេទាំងអស់គ្នា**"។ ថ្ងៃនេះព្រះវិញ្ញាណដ៏វិសុទ្ធនៅលើបងប្អូនទាំងអស់ ដើម្បីឲ្យបងប្អូនទៅជាព្យាការីជាអ្នកថ្លែងដំណឹងល្អរបស់ព្រះជាម្ចាស់។ តែមិនមែនថ្លែងដោយបបូរមាត់ ឲ្យយើងយកចិត្តទុកដាក់ជួយបងប្អូនឯទៀតៗ។ ឲ្យយើងធ្វើអំពើល្អដោយសេចក្តីស្រឡាញ់ ដោយដៃរបស់ខ្ញុំ ដោយភ្នែករបស់ខ្ញុំ ដោយជើងរបស់ខ្ញុំ ដែលព្រះយេស៊ូណែនាំ ដើម្បីឲ្យយើងទៅជាព្យាការីយ៉ាងពិតប្រាកដ។ ព្រះវិញ្ញាណដ៏វិសុទ្ធ ឲ្យយើងសប្បាយចិត្ត ដោយសារព្រះជាម្ចាស់បានចែករំឡែកព្រះវិញ្ញាណដ៏វិសុទ្ធ ស្មើៗគ្នាតាមសមត្ថភាពរៀងៗខ្លួន ដើម្បីឲ្យយើងមានកម្លាំងបង្កើតផលផ្លែយ៉ាងច្រើននៅក្នុងជីវិតផ្ទាល់ខ្លួននិងពិភពលោកដែរ។ ផ្លែផលគឺ ចិត្តស្រឡាញ់ ចិត្តមេត្តា ចិត្តលើកលែងទោស ចិត្តបរិសុទ្ធ ជំនឿ ជាផ្លែផលនៃព្រះវិញ្ញាណដ៏វិសុទ្ធដែលយើងអាចមើលឃើញជាក់ស្តែង។ ឲ្យយើងចាប់ផ្តើមពីយើងដើម្បីឲ្យយើងសង្ឃឹមបន្តិចម្តងៗនៅគ្រប់ទីកន្លែងយើងមានសេចក្តីសុខ នៅគ្រប់ទីកន្លែងមានព្រះជាម្ចាស់គង់នៅ។ យើងសម្លឹងមើលព្រះយេស៊ូលើឈើឆ្កាង ដោយដឹងថាព្រះយេស៊ូសោយទិវង្គត ប៉ុន្តែព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ មានន័យថាព្រះយេស៊ូមានជីវិតអស់កល្បជានិច្ច និងព្រះយេស៊ូធ្វើដំណើរជាមួយយើងតទៅទៀត។

ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គជួយទាំងដៃ ទាំងជើង ទាំងភ្នែក របស់យើង ឲ្យពោរពេញដោយធម៌មេត្តាករុណារបស់ព្រះអង្គនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលណែនាំឲ្យយើងមានយោបល់ល្អជានិច្ច ឲ្យយើងចេះទទួលខុសនិងត្រូវជានិច្ច ឲ្យយើងមានប្រាជ្ញាឈ្លៀសវៃជានិច្ច និងជាពិសេសឲ្យយើងទុកឲ្យព្រះជាម្ចាស់ដឹកនាំជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ។ យើងចូលរួមជាមួយបងប្អូនដែលទទួលអគ្គសញ្ញាលាបថ្ងាសបន្តិចទៀត ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ដូចពីសម័យដើមដែលព្រះអង្គបានប្រទានឲ្យក្រុមគ្រីស្តទូត។ អាម៉ែន៕